**សហព័ន្ធ ស្រូវ អង្ករ កម្ពុជា**
**Cambodia Rice Federation**

លេខ៖ ០០.៧៧../១៥ ស.អ.ក

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រមូលប្រាក់សមាជិកភាព របស់សមាជិកសហព័ន្ធស្រូវអង្ករកម្ពុជា

( CRF's Membership Fee )

**យោង៖** - លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហព័ន្ធ ដែលបានអនុម័តដោយមហាសន្និបាតរបស់សហព័ន្ធ កាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥។

- លទ្ធផលនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល កាលពីថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៥។

សហព័ន្ធស្រូវអង្ករកម្ពុជា មានកិត្តិយសសូមជម្រាបជូនដល់ សមាជិក សមាជិកា ទាំងអស់មេត្តាជ្រាបថា៖ ដើម្បីជាការចូលរួមជួយទ្រទ្រង់ឲ្យកិច្ចដំណើរការអនុវត្តនូវ "ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ឆ្នាំ២០១៥ (ផែនការមាស ស)របស់សហព័ន្ធ" ទទួលបាននូវភាពជោគជ័យជាបន្តបន្ទាប់នោះ ចាំបាច់ត្រូវមានការចូលរួមសហការយ៉ាងជិតស្និទ ពីសំណាក់សមាជិកសមាជិកាទាំងអស់ រួមមាន ទាំងផ្នែកស្មារតី ផ្នែកសម្ភារៈ បច្ចេកទេស និងថវិកា ជាដើម។

ដើម្បីមានភាពងាយស្រួលច្បាស់លាស់ពីនីតិវិធីនានា និងឲ្យមានតម្លាភាពចំពោះសមាជិកទាំងឡាយណាដែលបានបំពេញកាតព្វកិច្ចត្រឹមត្រូវជាសមាជិកភាព សហព័ន្ធស្រូវអង្ករកម្ពុជា សូមជូនដំណឹងដល់សមាជិកទាំងអស់មេត្តាជ្រាបថា សមាជិកទាំងអស់មានកាតព្វកិច្ចត្រូវបង់ **ប្រាក់សមាជិកភាព**( Membership Fee ) ចំនួន២០០ដុល្លាក្នុងមួយឆ្នាំ។

សម្រាប់ឆ្នាំ២០១៥នេះ សហព័ន្ធស្រូវអង្ករកម្ពុជា បានចាប់ផ្តើមប្រមូលប្រាក់សមាជិកភាពចាប់ពីថ្ងៃទី០១ ខែមិថុនា រហូតដល់ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ ខាងមុខនេះ ដោយសហព័ន្ធ បានកំណត់យកថ្ងៃទី០១ ខែមិថុនា ជារៀងរាល់ឆ្នាំ ជាការចាប់ផ្តើមប្រមូលនូវប្រាក់សមាជិកភាពពីសមាជិកទាំងអស់។

**សូមបញ្ជាក់ថា** សហព័ន្ធ នឹងសូមផ្តល់អត្ថប្រយោជន៍នានារបស់សហព័ន្ធ ជូនទៅសមាជិកវិញ ដោយនឹងផ្តល់អាទិភាពមុនគេ ដល់សមាជិកទាំងឡាយណាដែលបានគោរពទៅតាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហព័ន្ធ និងបានបំពេញកាតព្វកិច្ចជាសមាជិករបស់សហព័ន្ធ ដូចជា បានបង់នូវប្រាក់សមាជិកភាព និងចូលរួមបង់ប្រាក់វិភាគទានសម្រាប់ការនាំចេញ( សម្រាប់ក្រុមហ៊ុននាំចេញ ) ជាដើម។

សូមទំនាក់ទំនងមកកាន់លេខាធិការដ្ឋាន ស.អ.ក៖

កញ្ញា ធឿន សុវឌ្ឍនា គណនេយ្យករ ទូរស័ព្ទ៖ 087-55 98 99



#2C, Street 120, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, Cambodia • Tel: +855 23 722 250 • Mail: info@crf.org.kh

ឬ ផ្ទេរចូលលេខគណនេយ្យរបស់សហព័ន្ធ៖

1. ធនាគារ FTB:
   - Account Name: Cambodia Rice Federation
   - Account Number: 010.30.062.002453.6
2. Wing:
   - To Cambodia Rice Federation
   - Phone Number: 087-55 98 99

សហព័ន្ធ សូមបញ្ជាក់និងធានាអះអាងថា រាល់ការចូលរួមវិភាគទានផ្សេងៗរបស់សមាជិកទាំងអស់ គឺត្រូវបានកត់ត្រាត្រឹមត្រូវច្បាស់លាស់តាមរយៈប្រព័ន្ធគណនេយ្យ និងការប្រើប្រាស់ប្រកបដោយតម្លាភាព ដើម្បីជាប្រយោជន៍រួមដល់សមាជិកសមាជិការបស់សហព័ន្ធស្រូវអង្ករកម្ពុជាទាំងមូល។

ក្នុងនាមក្រុមប្រឹក្សាភិបាលសហព័ន្ធ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់សមាជិកសមាជិកាទាំងអស់ដែលបានបំពេញកាតព្វកិច្ចជាសមាជិក និងសង្ឃឹមយ៉ាងមុតមាំថា សមាជិកសមាជិកាទាំងឡាយណា ដែលមិនទាន់បានបំពេញកាតព្វកិច្ចរបស់ខ្លួន សូមមេត្តាជ្រាប និងផ្តល់នូវកិច្ចសហការដល់ក្រុមការងារលេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា ដោយក្តីអនុគ្រោះ។

សូម សមាជិកសមាជិកានៃសហព័ន្ធទាំងអស់ ទទួលនូវការគោរពរាប់អាន ពីយើងខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥

**ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា**

**ប្រធាន**

CAMBODIA RICE FEDERATION

**សុខ ពុទ្ធីវុធ**

<u>**សូមជូនភ្ជាប់នូវ៖**</u>

1. បញ្ជីឈ្មោះក្រុមហ៊ុន បានបង់ប្រាក់សមាជិកភាពរួច ០១ច្បាប់